# ទិដ្ឋភាពទូទៅនៃកម្មវិធី៖
# «មូលនិធិដំឡើងស្នាដៃថ្មី ឆ្នាំ២០២៤»
## ស្នាដៃសិល្បទម្រង់ទស្សនីយភាព ក្រោមមូលបទ «សិល្បៈនិងសង្គម»

សិល្បៈខ្មែរអមតៈ

**១. តើមូលនិធិដំឡើងស្នាដៃថ្មីមានន័យដូចម្តេច? តើមូលនិធិនេះមានប្រតិបត្តិការដូចម្តេច?**

មូលនិធិដំឡើងស្នាដៃថ្មី ត្រូវបានបង្កើតឡើងសម្រាប់គាំទ្រដល់សិល្បករ សហគមន៍សិល្បៈ ដើម្បីឱ្យពួកគាត់មានឱកាសក្នុងការបញ្ចេញភាពច្នៃប្រតិដ្ឋតាមរយៈ ការបង្កើតស្នាដៃថ្មី ឬ អភិវឌ្ឍស្នាដៃថ្មីដែលមានស្រាប់ នៅក្រោមទម្រង់សិល្បទស្សនីយភាព និងអនុញ្ញាឱ្យពួកគាត់ អាចចែករំលេកអំពីរឿងរ៉ាវដែលមានអត្ថន័យ នៅក្នុងសង្គមបច្ចុប្បន្ន ទៅកាន់សាធារណៈជនផងដែរ។ នៅក្នុងមូលបទនេះ សិល្បករអាចបង្ហាញជ្រុងណានៃទិដ្ឋភាព ឬរឿងរ៉ាវនៅក្នុងសង្គមដូចជា៖ បញ្ហាបំរែបំរួលអាកាសធាតុ ការអភិវឌ្ឍទីក្រុងជាដើម។ ចាប់ពីពេលបង្កើតនៅឆ្នាំ២០១៨មក រាល់ស្នាដៃរបស់មូលនិធិដំឡើងស្នាដៃថ្មី ត្រូវបានយកទៅដាក់បង្ហាញ (សម្តែងផ្ទាល់) នៅក្នុងកម្មវិធីរដូវវប្បធម៌នៅភ្នំពេញ និងតាមបណ្តាខេត្តនានាជាមួយនឹង ប្រធានបទផ្សេងៗក្នុងឆ្នាំនិមួយៗ ។ ប៉ុន្តែនៅឆ្នាំ២០២៤នេះ សិល្បៈខ្មែរអមតៈបានរៀបចំមូលនិធិនេះ នៅក្នុងទម្រង់ថ្មីនេះនឹងចែកចេញជា ៣ ស្រទាប់ ពោលគឺ៖

- ទី១ "ការអនុវត្ត គម្រោងមូលនិធិដំឡើងស្នាដៃថ្មី ។
- ទី២ "អ្នកប្រឹក្សាផ្នែកសិល្បៈ" សិល្បករនឹងធ្វើការដោយ ផ្ទាល់ជាមួយអ្នកប្រឹក្សា ដែលខ្លួនជ្រើសរើស ពីពេលចាប់ផ្តើមរហូតដល់បញ្ចប់ការដំឡើងស្នាដៃ ដើម្បីជម្រុញទៅលើភាពស៊ីជម្រៅ និងគុណភាពនៃស្នាដៃ ។
- និងទី៣ "ការធ្វើបទ បង្ហាញ" សិល្បករត្រូវធ្វើការបង្ហាញដោយខ្លួនឯង (កុងត្រាដាច់ដោយឡែក) នៅទីតាំងនិងកាលបរិច្ឆេទដាក់លាក់ណាមួយ ។ ទម្រង់ថ្មីនេះនឹងអនុញ្ញាតឱ្យសិល្បករអាចជ្រើសរើសពេលវេលាសមស្របណាមួយ ដើម្បីបង្ហាញស្នាដៃរបស់ពួកគេដោយមិនមានការ ប៉ះពាល់ទៅដល់កាលវិភាគ របស់ពួកគាត់និងសិល្បៈខ្មែរអតមៈ ។ លើសពីនេះយើងក៏មានបំណងជ្រើសរើសស្នាដៃទាំងនោះទៅដាក់បង្ហាញ ក្នុងអំឡុងពេលដំណើរទស្សនាចរណ៍តាម ខេត្តដែលដឹកនាំដោយក្រុមរថយន្តតន្ត្រីទិព្វខ្មែរនៅចុងឆ្នាំនេះផងដែរចន្លោះ ខែ វិច្ឆិកា-ធ្នូ ឆ្នាំ ២០២៤ ។

**២. តើគោលដៅរបស់មូលនិធិមានអ្វីខ្លះ?**

មូលនិធិ «ដំឡើងស្នាដៃថ្មី» បង្កើតឡើងដើម្បី៖

- លើកទឹកចិត្តសិល្បករឱ្យបង្កើតភាពច្នៃប្រតិដ្ឋកាន់តែច្រើន តាមរយៈការបង្កើតស្នាដៃថ្មី ឬ ការអភិវឌ្ឍស្នាដៃថ្មីដែលមានស្រាប់ ។
- ជួយបង្កើតជាវេទិកាមួយសម្រាប់សិល្បករធ្វើការចែករំលែកនិងឆ្លុះបញ្ចាំងអំពីសង្គមកម្ពុជានាពេលបច្ចុប្បន្ន តាមរយៈស្នាដៃច្នៃប្រតិដ្ឋរបស់ខ្លួន ។
- ចូលរួមអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សិល្បករ ។

**៣. តើអត្ថប្រយោជន៍នៃមូលនិធិនេះមានអ្វីខ្លះ?**

សិល្បករនឹងទទួលបានប្រាក់ឧបត្ថម្ភ ឬ មូលនិធិរហូតដល់ ៦.០០០ដុល្លារអាមេរិក ដោយយោងតាមរចនាសម្ព័ន្ធនៃមូលនិធិដំឡើងស្នាដៃថ្មី ដែលមានបីស្រទាប់៖

- មូលនិធិចំនួន ៤.០០០ដុល្លារអាមេរិក សម្រាប់ដំណើរការនៃការដំឡើងស្នាដៃថ្មី ។
- មូលនិធិចំនួន ១.០០០ ដុល្លារអាមេរិក សម្រាប់អ្នកប្រឹក្សាផ្នែកសិល្បៈ ។
  - បេក្ខជនត្រូវតែមានអ្នកប្រឹក្សាយោបល់ផ្នែកសិល្បៈក្នុងការដំឡើងស្នាដៃនេះ ។
- មូលនិធិចំនួន ១.០០០ ដុល្លារអាមេរិក សម្រាប់បង្ហាញស្នាដៃនៅពេលបញ្ចប់
  - បេក្ខជនត្រូវធ្វើការដាក់បង្ហាញស្នាដៃសម្តែងផ្ទាល់ បន្ទាប់ពីបញ្ចប់ការដំឡើងរួចរាល់ ដែលនឹងទទួលបានមូលនិធិឧបត្ថមដោយឡែក សម្រាប់ដាក់ បង្ហាញស្នាដៃថ្មីនេះ ដោយយោងទៅតាមកាលវិភាគ ទីតាំង និងអ្នកទស្សនាគោលដៅ ដែលមានចែងនៅក្នុងផែនការគម្រោងរបស់អ្នកច្បាស់លាស់ ។

## ៤. តើនរណាជាអ្នកចូលរួមគោលដៅសម្រាប់មូលនិធិនេះ?

- សិល្បករវ័យក្មេង ឬ ជាសិល្បករមានពិសោធន៍ច្រើនគួរសម ហើយមានការតាំងចិត្តខ្ពស់ចំពោះអាជីពរបស់ខ្លួន ។
- សិល្បករដែលធ្វើការក្នុងផ្នែកសិល្បទស្សនីយភាព (មានដូចជា ល្ខោន របាំ តន្ត្រី) ឬជាសិល្បករដែលធ្វើការលើពហុទម្រង់ តែត្រូវយកទម្រង់សិល្បទស្សនីយភាពជាគោល (ដូចជា ល្ខោននិងសិល្បៈបង្គុំ, តន្ត្រីនិងគំនូរ, របាំនិងកុន ។ល។) ។
- សិល្បករឯកត្តបុគ្គល ឬ ជាក្រុមសិល្បករ ឬ ជាសិល្បៈសហគមន៍ (ចំពោះក្រុមសិល្បករ ឬ សិល្បៈសហគមន៍ សូមដាក់ឈ្មោះតែអ្នកតំណាងក្រុមបានហើយនៅក្នុងពាក្យស្នើសុំ) ។

## ៥. តើលក្ខខណ្ឌជ្រើសរើសសម្រាប់មូលនិធិនេះមានអ្វីខ្លះ?

ដើម្បីអាចដាក់ពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មីបាន បេក្ខជនត្រូវតែមានលក្ខណៈគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ស្នាដៃដែលគ្រោងបង្កើតថ្មី ឬក៏ជាស្នាដៃបង្កើតថ្មីដែលមានស្រាប់ តែត្រូវការការអភិវឌ្ឍបន្ថែម ។ រីឯស្នាដៃដែលមានស្រាប់ ហើយពុំមានគម្រោងយកមកអភិវឌ្ឍបន្ថែមនោះទេ ស្នាដៃនោះពុំមានសិទ្ធិស្នើសុំមូលនិធិបានឡើយ ។
- បេក្ខជនអាចដាក់ពាក្យស្នើសុំជាលក្ខណៈបុគ្គល ឬ ជាក្រុមតែក្រុមនោះមិនត្រូវមានសមាជិកលើសពី ៨ នាក់ឡើយ ។
- ស្នាដៃដែលមានរយៈពេលសម្តែងចន្លោះ ៣០ នាទី ទៅ ៤៥ នាទី ។
- ពាក្យស្នើសុំ អាចសរសេរជាភាសាខ្មែរក៏បាន ឬ ភាសាអង់គ្លេសក៏បាន ឬ ថតចម្លើយជាវីដេអូក៏បានឬជាសំឡេងក៏បាន ហើយអាចសរសេរដៃក៏បានឬដោយកុំព្យូទ័រក៏បាន ។ ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមអញ្ជើញទាក់ទងមកលេខ ០១០ ៤៨៣ ៩៤៧/០៧៧ ៧៩៣ ៥៣៧ ។
- ចូរបញ្ជូនពាក្យស្នើសុំតាមរយៈអ៊ីម៉ែល samath@cambodianlivingarts.org ឬអាចយកពាក្យស្នើសុំទៅដាក់ផ្ទាល់នៅការិល័យអង្គការសិល្បៈខ្មែរអមតៈ (អាសយដ្ឋានការិយាល័យអង្គការសិល្បៈខ្មែរអមតៈ ៖ ផ្ទះលេខ១១៣E ផ្លូវលេខ៨៣០ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ) ។
- អាចដាក់ពាក្យស្នើសុំជាលក្ខណៈបុគ្គល ឬ ជាក្រុម (ចំពោះការដាក់ពាក្យស្នើសុំលក្ខណៈជាក្រុម

សូមដាក់ឈ្មោះតែអ្នកតំណាងក្រុមបានហើយ) ។

- បេក្ខជនត្រូវពន្យល់ប្រាប់ពីមូលហេតុក្នុងការជ្រើសរើសយកអ្នកប្រឹក្សាផ្នែកសិល្បៈមកជួយនៅក្នុងគម្រោងរបស់ខ្លួន ។
    - លក្ខណសម្បត្តិ ។
    - ភាពស៊ីគ្នានៃចំណេះ និងជំនាញអ្នកប្រឹក្សាសិល្បៈទៅនឹងគម្រោងដែលស្នើសុំ
- ជាបេក្ខជនដែលកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា អំឡុងពេលនៃការអនុវត្តគម្រោង និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន ឬ ទិដ្ឋាការ K-Visa ។

## ៦. តើដំណើរការនៃការជ្រើសរើសសម្រាប់មូលនិធិនេះ មានអ្វីខ្លះ?

- នៅពេលលោកអ្នកផ្ញើពាក្យស្នើសុំមកកាន់ពួកយើង ពួកយើងនឹងបញ្ជាក់ប្រាប់វិញ ប្រសិនបើពួកយើងបានទទួល ។
- ប្រសិនបើលោកអ្នកមិនបានទទួលដំណឹងពីពួកយើងក្នុងអំឡុងពេល ៣ ថ្ងៃ នៃថ្ងៃធ្វើការទេនោះ សូមទាក់ទងមកពួកយើងម្តងទៀត ។
- បន្ទាប់កាលបរិច្ឆេទឈប់ទទួលពាក្យ ពួកយើងនឹងធ្វើការពិនិត្យមើលពាក្យស្នើសុំភ្លាមៗ
- ពាក្យស្នើសុំទាំងអស់ដែលត្រឹមត្រូវតាមលក្ខខណ្ឌ នឹងត្រូវបានពិនិត្យម្តងទៀតដោយ យោងទៅតាមលក្ខខណ្ឌនៃការជ្រើសរើសដែលបានកំណត់ខាងលើ
    - ការពិនិត្យមើលនេះ នឹងត្រូវបានធ្វើឡើងដោយគណៈកម្មការជ្រើសរើសឯករាជ្យ ។
    - ប្រព័ន្ធផ្តល់ពិន្ទុនឹងត្រូវបានប្រើដើម្បីឱ្យការផ្ទៀងផ្ទាត់ពាក្យស្នើសុំមានភាពត្រឹមត្រូវល្អ ។
- បេក្ខជនដែលបានជាប់ដំណាក់កាលពិនិត្យពាក្យស្នើសុំ នឹងត្រូវបានអញ្ជើញ មកធ្វើ សម្ភាសន៍នៅទីតាំងការិយាល័យរបស់ «សិល្បៈខ្មែរអមតៈ»
    - កិច្ចសម្ភាសន៍ នឹងត្រូវបានធ្វើឡើងនៅ**ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០២៤ ។**
- បេក្ខជនដែលបានជ្រើសរើស ពួកយើងនឹងជម្រាបដំណឹងជូននៅចន្លោះ **ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០២៤ ។**
- បេក្ខជនទាំងអស់ នឹងត្រូវបានជម្រាបជូនអំពីលទ្ធផលជ្រើសរើសនៅត្រឹម **ថ្ងៃទី ៨ ដល់ ទី ១២ ខែកក្កដា ឆ្នាំ ២០២៤ ។**

## ៧. តើគ្រោងនិងពេលរបស់មូលនិធិគឺជាអ្វី?

គ្រោងនិងពេលរបស់មូលនិធិ គឺការការបរិច្ឆេទពេលវេលាគម្រោងនឹងត្រូវធ្វើនៅចន្លោះ **ខែកក្កដា ដល់ ខែធ្នូ ឆ្នាំ ២០២៤ ។**

## ៨. តើនរណាជា «អ្នកសម្របសម្រួល / អ្នកប្រឹក្សា / ក្រុមការងារពាក់ព័ន្ធ»?

- គណៈកម្មការឯករាជ្យចំនួន៣រូបនឹងដាក់ពិន្ទុជ្រើសរើសបេក្ខជនយ៉ាងសុក្រិត្យនិងតម្លាភាព ។
- មូលនិធិនេះនឹងសម្របសម្រួលដោយក្រុមការងារអង្គការសិល្បៈអមតៈ លោក ថា សំអាត ដែលមានលេខទូរសព្ទ័ ០៧៧ ៧៩ ៣៥ ៣៧ / ០១០ ៤៨ ៣៩ ៤៧ និង អ៊ីម៉េល samath@cambodianlivingarts.org ។

## ៩. កាលបរិច្ឆេទសំខាន់ៗ

| កាលបរិច្ឆេទ | ម៉ោង | សកម្មភាព |
|---|---|---|
| ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០២៤ | ៥:០០នាទី ល្ងាច | ប្រកាសជ្រើសរើសអ្នកទទួលមូលនិធិដំឡើងស្នាដៃថ្មី |
| ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២៤ | ៥:៣០ - ៧:០០នាទី ល្ងាច | វគ្គសំណួរនិងចម្លើយតាមហ្សូម |
| ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៤ | ៥:០០នាទី ល្ងាច | ផុតកំណត់ទទួលពាក្យ |
| ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០២៤ | ជូនដំណឹងតាមក្រោយ | សម្ភាសន៍បេក្ខជនដែលជាប់វគ្គជម្រុះ |
| ថ្ងៃទី ៨-១២ ខែកក្កដា ឆ្នាំ ២០២៤ | ៥:០០ នាទី ល្ងាច | ប្រកាសជ័យលាភីអ្នកទទួលមូលនិធិដំឡើងស្នាដៃថ្មី |
| ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០២៤ | ជូនដំណឹងតាមក្រោយ | អ្នកសម្របសម្រួលមូលនិធិជួបជាមួយអ្នកទទួលបានមូលនិធិទាំង៤<br>ដើម្បីនែនាំខ្លួននិងប្រាប់ពីដំណើរការលំ អិតនៃមូលនិធិ ណែនាំពន្យល់ពីឯកសារចាំបាច់ដែល ត្រូវការដូចជាៈ កិច្ចព្រមព្រៀង របាយការណ៍ហិរញ្ញវត្ថុ ពាក្យស្នើសុំពន្យាពេល និងឯកសារតាមដាននិងវាយតម្លៃដំណើរការណ៍នៃការដំឡើងស្នាដៃនេះ |
| ងៃទី ២១ ខែកក្កដា ឆ្នាំ ២០២៤ | ជូនដំណឹងតាមក្រោយ | សិក្ខាសាលាបណ្តុះបណ្តាលអំពីមូលដ្ឋាគ្រឹះនៃការគ្រប់គ្រងនិងដឹកនាំគម្រោងទៅបេក្ខជនទាំងអស់ |
| ខែកក្កដា - តុលា ឆ្នាំ ២០២៤ | ជូនដំណឹងតាមក្រោយ | ការចុះត្រួតនិងគាំទ្រដល់ដំណើរការនៃការដំឡើងស្នាដៃ (ក្រុមការងារនឹងបញ្ជាក់ពេលក្រោយ) |
| ខែវិច្ឆិកា - ខែធ្នូ ឆ្នាំ ២០២៤ | | បញ្ចប់ដំណើរការដំឡើងស្នាដៃ<br>**បញ្ជាក់៖** អ្នកត្រូវតែបញ្ចប់ការដំឡើងស្នាដៃរបស់អ្នកនៅចន្លោះ ខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ២០២៤ ជាកំហិត |